# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកិលានុបដ្ឋាកកម្ពុជា
CAMBODIAN COUNCIL OF NURSES

# ផែនការយុទ្ធសាស្ត្រ
# ២០២១-២០២៥
# របស់គណៈកិលានុបដ្ឋាកកម្ពុជា

សហការរៀបចំ និង ឧបត្ថម្ភដោយ

USAID
FROM THE AMERICAN PEOPLE

fhi 360
THE SCIENCE OF IMPROVING LIVES

# អារម្ភកថា

ផែនការយុទ្ធសាស្ត្រឆ្នាំ ២០២១-២០២៥ របស់គណៈគិលានុបដ្ឋាកកម្ពុជានេះត្រូវបានរៀបចំឡើងដោយក្រុមការងារដែលដឹកនាំដោយគណៈគិលានុបដ្ឋាកកម្ពុជាក្រោមកិច្ចសហការនិងឧបត្ថម្ភគាំទ្រដោយគម្រោងលើកកម្ពស់គុណភាព សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក (USAID-EQHA) ដែល អនុវត្តដោយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)។ ផែនការយុទ្ធសាស្ត្រនេះគឺបង្កើតឡើងដើម្បីចង្អុលបង្ហាញដល់ថ្នាក់ដឹកនាំគណៈគិលានុបដ្ឋាកកម្ពុជា ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិយកទៅអនុវត្តដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗទាំងឡាយនៅមុនបំណាច់ឆ្នាំ ២០២៥។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនចំពោះក្រុមការងារទាំងអស់ដែលបានចូលរួម ផ្តល់ជាមតិយោបល់និងគំនិតថ្មីៗផ្សេងៗយ៉ាងសកម្មជាទីបំផុត។ប្រសិនបើគ្មានការចូលរួមពីលោកនិងលោកស្រី ជាក្រុមការងារទាំងអស់ដោយមិនខ្លាចពីភាពហត់នឿយនោះទេផែនការយុទ្ធសាស្ត្រឆ្នាំ ២០២១-២០២៥ របស់គណៈគិលានុបដ្ឋាកកម្ពុជាក៏មិនអាចលេចរូបរាងបានឡើយ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង ឯកឧត្តមសាស្ត្រាចារ្យ **ឆា គ្រុយ** រដ្ឋលេខាធិការក្រសួងសុខាភិបាលនិងជា ប្រធានគណៈកម្មការសម្របសម្រួលគណៈវិជ្ជាជីវៈសុខាភិបាលទាំងប្រាំដែលតែងតែយកចិត្តទុកដាក់ផ្តល់ការណែនាំនិងសម្របសម្រួលជានិច្ចជាកាលក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនេះក៏ដូចជាក្នុងអំឡុងពេលអនុវត្តសកម្មភាពរបស់គណៈគិលានុបដ្ឋាកកម្ពុជាផងដែរ។

ជាទីបញ្ចប់ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់គម្រោងលើកកម្ពស់គុណភាពសេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក (USAID-EQHA) ដែលអនុវត្តដោយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)ដែលបានជួយឧត្ថម្ភទាំងបច្ចេកទេសនិងថវិកាដល់គណៈគិលានុបដ្ឋាកកម្ពុជាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ ២០២១-២០២៥ នេះប្រកបដោយជោគជ័យ។

ថ្ងៃ សុក្រ ១៣ កើតខែ ចេត្រ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

**ប្រធាន**

**អនុបណ្ឌិត អ៊ុន សាន**

# មាតិកា


មាតិកា....................3

ផ្នែកទី១....................4

សេចក្តីផ្តើម៖....................4

ផ្នែកទី២....................5

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២១-២០២៥....................5

ផ្នែកទី៣....................7

ទស្សនៈវិស័យ បេសកកម្ម និងគោលការណ៍មគ្គុទេសក៍នៃគុណតម្លៃ....................7

ផ្នែកទី៤....................8

ការវិភាគស្ថានភាព ចំណុចខ្លាំង ចំណុចខ្វះខាត ឱកាស និងការប្រឈម( SWOT-Analysis )....................8

១. ការវិភាគយុទ្ធសាស្ត្រ (ការវិភាគលើកត្តាអត្តនោម័ត និងសត្យាម័ត) (SWOT-Analysis) របស់ គ.គិ.ក....................8

២. ការគំរាមកំហែង....................11

៣. គោលបំណង និងផ្នែកនៃការងារ....................11

សេចក្តីបន្ថែមទី ១៖ បញ្ជីឈ្មោះសមាជិកក្រុមការងារបច្ចេកទេស....................27

សេចក្តីបន្ថែមទី២៖ បញ្ជីឈ្មោះក្រុមការងារចូលរួមសិក្ខាសាលាពិគ្រោះយោបល់....................29

# ផ្នែកទី១

## សេចក្តីផ្តើម៖

គណៈគិលានុបដ្ឋាកកម្ពុជា ត្រូវបានបង្កើតឡើងក្រោមព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧។

### អំពីគណៈគិលានុបដ្ឋាកកម្ពុជា(គ.គ.ក)

គណៈគិលានុបដ្ឋាកកម្ពុជា(គ.គ.ក) គឺជាអញ្ញាធរដែលមានលក្ខន្តិកៈហើយមានស្វ័យភាពក្នុងការចំណាយការផ្គត់ផ្គង់ថវិកាក្រោមព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជាឆ្នាំ២០០៧។

### ភារកិច្ចរបស់គិលានុបដ្ឋាកកម្ពុជា(គ.គ.ក)

គ.គ.ករៀបចំនិងថែរក្សាជាប្រចាំបញ្ជីរាយនាមគិលានុបដ្ឋាក-យិកាដែលបំពេញគ្រប់ល័ក្ខខ័ណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ស្របទៅតាមលក្ខខណ្ឌរបស់គ.គ.កក្នុងការចុះបញ្ជិកាគណៈគិលានុបដ្ឋាកនៅព្រះរាជាណាចក្រកម្ពុជា[២]។

គ.គ.ក គឺជា ស្ថាប័នតែមួយគត់ដែលមានអំណាចឃ្លាំមើលការប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាកនៅកម្ពុជា។

### កិច្ចការបន្ត

គណៈគិលានុបដ្ឋាកបំពេញការងាររបស់ខ្លួនតាមរយៈក្រុមប្រឹក្សារាជធានី-ខេត្តនិងភូមិភាគដោយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ[៣]នឹងត្រូវរាយការណ៍ជូនក្រសួងសុខាភិបាល។

### គោលបំណងនៃផែនការយុទ្ធសាស្រ្ត

**១.** បញ្ជាក់ថាជាសមាជិករបស់គ.គ.កដើម្បីចុះឈ្មោះក្នុងបញ្ជិកាគណៈគិលានុបដ្ឋាកកម្ពុជាទាំងគិលានុបដ្ឋាកកម្ពុជា និងបរទេស ។

**២.** បង្កើតការយល់ដឹងសម្រាប់សមាជិក គ.គ.ក អំពីតួនាទី និងគោលបំណង គ.គ.ក សម្រេចបាន។

**៣.** ផ្តល់មូលដ្ឋានសំរាប់ការបែងចែកកិច្ចការ ក្នុងគោលបំណងដើម្បី សម្រេចបានចក្ខុវិស័យ និង បេសកកម្មរបស់ខ្លួន។

[២] ផ្នែកទី២ មាត្រា៥ នៃព្រះរាជក្រម [៣] ផ្នែកទី២ មាត្រា៥ នៃព្រះរាជក្រឹត្យ

# ផ្នែកទី២

## ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២១-២០២៥

ការរៀបចំផែនការយុទ្ធសាស្ត្ររបស់គណៈគិលានុបដ្ឋាកកម្ពុជាចែកចេញជា ៥ ដំណាក់កាល៖

- **ដំណាក់កាលទី១៖** ជួបប្រជុំជាមួយសមាជិកក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកកម្ពុជានិងក្រុមការងាររបស់អង្គការគ្រួសារអន្តរជាតិ (Fhi360) តាមរយៈការអនុវត្តគម្រោងលើកកម្ពស់គុណភាពសេវាថែទាំសុខភាពរបស់ជំនួយទីភ្នាក់ងារសហរដ្ឋអាមេរិក (USAID-EQHA) ដើម្បីរៀបចំបង្កើតមគ្គុទេសក៍ដើម្បីចង្អុលបង្ហាញពីរបៀបនិងយុទ្ធសាស្ត្រផ្សេងៗក្នុងការសរសេរផែនការយុទ្ធសាស្ត្រ។
- **ដំណាក់កាលទី២៖** សិក្ខាសាលារួមគ្នាលើកទី១ត្រូវបានរៀបចំឡើងចំនួនពីរថ្ងៃគឺដោយគិតចាប់ពីថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២០ ដើម្បីតម្រង់ទិសនៃការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២១-២០២៥ របស់គណៈវិជ្ជាជីវៈសុខាភិបាល។ ការពិគ្រោះយោបល់និងពិភាក្សាគ្នាជាក្រុម របស់គណៈវិជ្ជាជីវៈសុខាភិបាលទាំង៥ បានធ្វើឡើងរៀងៗខ្លួនក្រោមជំនួយបច្ចេកទេសនៃក្រុមការងារគម្រោង USAID-EQHA តាមរយៈទីប្រឹក្សាបច្ចេកទេសទាំងជាតិ និងអន្តរជាតិដោយផ្តើមឡើងពីការពិនិត្យឡើងវិញពីផែនការយុទ្ធសាស្ត្រថ្នាក់ជាតិរួមគ្នារបស់គណៈវិជ្ជាជីវៈសុខាភិបាលឆ្នាំ២០១៥-២០២០ ការពិភាក្សាពីចំណុចដែលបានអនុវត្តនិងចំណុចដែលមិនទាន់បានអនុវត្ត បញ្ហាប្រឈមនានា ដំណោះស្រាយ ដែលបានអនុវត្តនៅរយៈពេល៥ឆ្នាំកន្លងមកត្រូវបានលើកយកមកចែករំលែកនិងយកជាមូលដ្ឋានគ្រឹះនៅក្នុងការរៀបចំបង្កើត ទស្សនៈវិស័យ បេសកកម្ម និងគុណតម្លៃសម្រាប់រយៈពេល៥ឆ្នាំបន្ត។ ការកំណត់វត្ថុបំណង សកម្មភាពយុទ្ធសាស្ត្រក៏ត្រូវបានលើកយកមកពិភាក្សានិងធ្វើលំហាត់រួមគ្នាផ្ទាល់នៅក្នុងសិក្ខាសាលាផងដែរ។ បន្ទាប់មកមន្ត្រី ចំនួន០១រូប របស់គណៈគិលានុបដ្ឋាកកម្ពុជាត្រូវបានជ្រើសរើសឱ្យទទួលខុសត្រូវលើសកម្មភាពបន្តជាមួយនឹងទីប្រឹក្សាបច្ចេកទេសរបស់ USAID-EQHA សម្រាប់ការសរសេរផែនការយុទ្ធសាស្ត្រត្រូវបានចាត់តាំងឡើងដោយថ្នាក់ដឹកនាំនៃក្រុមប្រឹក្សារបស់គណៈគិលានុបដ្ឋាកកម្ពុជា។ សិក្ខាសាលានេះមានការចូលរួមពីសំណាក់ ថ្នាក់ដឹកនាំរបស់ក្រសួង សុខាភិបាល ថ្នាក់ដឹកនាំរបស់ក្រុមប្រឹក្សាគណៈវិជ្ជាជីវៈសុខាភិបាលទាំង៥ (រាជធានី-ខេត្ត) ថ្នាក់ដឹកនាំរបស់ ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក USAID ទីប្រឹក្សាបច្ចេកទេសជាតិ ទីប្រឹក្សាអន្តរជាតិ និងមន្ត្រីរបស់គម្រោងUSAID-EQHAសរុបចំនួន៦៣នាក់។
- **ដំណាក់កាលទី៣៖** មន្ត្រីរបស់គណៈគិលានុបដ្ឋាកកម្ពុជា០១រូបដែលបានទទួលចាត់តាំងជាអ្នកទទួលខុសត្រូវសម្រាប់ដំណើរការសរសេរផែនការយុទ្ធសាស្ត្របន្តសម្របសម្រួលដំណើរនិងកិច្ចពិភាក្សាផ្សេងៗជាមួយថ្នាក់ដឹកនាំរបស់គណៈគិលានុបដ្ឋាកកម្ពុជានិងបន្តសរសេរផែនការយុទ្ធសាស្ត្រដោយដើរតាមមគ្គុទេសក៍



CAMBODIA COUNCIL OF NURSES

ណែនាំដែលបានចង្អុលបង្ហាញនិងការបណ្តុះបណ្តាលដែលបានចូលរួមនៅក្នុងសិក្ខាសាលាតម្រង់ទិស លើកទី១ដោយសហការសម្របសម្រួលបច្ចេកទេស ពីសំណាក់ លោក លី ច័ន្ទវឌ្ឍនៈ ទីប្រឹក្សាបច្ចេកទេស ការអភិវឌ្ឍគណៈវិជ្ជាជីវៈសុខាភិបាលរបស់គម្រោង USAID-EQHA/FHI360។

- **ដំណាក់កាលទី៤៖** មន្ត្រីរបស់គណៈគិលានុបដ្ឋាកកម្ពុជាដែលទទួលខុសត្រូវលើការរៀបចំសរសេរផែនការយុទ្ធសាស្រ្តនិងគណៈគិលានុបដ្ឋាកកម្ពុជាក្រោមការសហការរបស់ទីប្រឹក្សាបច្ចេកទេសរបស់គម្រោង USAID-EQHA បានធ្វើការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីទទួលយក ធាតុចូល និងព័ត៌មានត្រឡប់ពីសំណាក់ដៃគូរអភិវឌ្ឍនានាទាំងជាតិ និងអន្តរជាតិដើម្បីធ្វើការរៀបចំបញ្ចប់ការសរសេរផែនការយុទ្ធសាស្រ្តជាស្ថាពរ។
- **ដំណាក់កាលទី៥៖**មន្ត្រីរបស់គណៈគិលានុបដ្ឋាកកម្ពុជាដែលទទួលខុសត្រូវលើការរៀបចំសរសេរផែនការយុទ្ធសាស្រ្តនិងគណៈគិលានុបដ្ឋាកកម្ពុជាក្រោមការសហការរបស់ទីប្រឹក្សាបច្ចេកទេសរបស់គម្រោង USAID-EQHA/FHI360 បានធ្វើការរៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់នូវផែនការយុទ្ធសាស្រ្តឆ្នាំ២០២១-២០២៥ របស់គណៈគិលានុបដ្ឋាកកម្ពុជា។



CAMBODIA COUNCIL OF NURSES

# ផ្នែកទី៣

## ទស្សនៈវិស័យ បេសកកម្ម និងគោលការណ៍មគ្គុទេសក៍នៃគុណតម្លៃ

### ៣.១ ទស្សនៈវិស័យ

គណៈគិលានុបដ្ឋាកកម្ពុជាប្តេជ្ញាចិត្ត បន្តអភិវឌ្ឍគុណភាពនិងនិយាម(ស្តង់ដារ) វិជ្ជាជីវៈថែទាំ ការពារសិទ្ធរបស់អតិថិជនដែលមកទទួលសេវាសុខភាព និង ការពារសិទ្ធិរបស់គិលានុបដ្ឋាកដោយផ្អែកលើគោលនយោបាយ ច្បាប់ និង យុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល ។

### ៣.២ បេសកកម្ម

- បន្តឃ្លាំមើលការប្រព្រឹត្តរបស់គិលានុបដ្ឋាកទាំងអស់ក្នុងប្រទេសកម្ពុជា(ជាតិនិងបរទេស)ឱ្យស្របតាមស្តង់ដារវិជ្ជាជីវៈ ដើម្បីការពារសិទ្ធិរបស់អតិថិជនដែលមកទទួលសេវាសុខាភិបាល ។
- បន្តអភិវឌ្ឍគុណភាពនៃការថែទាំ តាមរយៈការបង្កើនចំណេះដឹង ជំនាញបច្ចេកទេស និងឥរិយាបថល្អដល់គិលានុបដ្ឋាកទូទាំងប្រទេស។

### ៣.៣ គោលការណ៍មគ្គុទេសក៍នៃគុណតម្លៃ

តម្លៃនៃគណៈគិលានុបដ្ឋាកកម្ពុជា ឆ្លុះបញ្ចាំងពីចរិយា ឥរិយាបថ និង ចរិកលក្ខណៈរបស់គិលានុបដ្ឋាកដែលបង្ហាញតាមរយៈគុណភាពនៃការអនុវត្តឱ្យស្របតាមក្រមសីលធម៌ និងផ្តល់ការថែទាំព្យាបាលអ្នកជំងឺឱ្យមានគុណភាព។ តម្លៃនិងឥរិយាបថរបស់គណៈគិលានុបដ្ឋាកកម្ពុជាមាន៖

- ការគោរពនូវតម្លៃមនុស្ស
- សេចក្តីសុច្ចរិត
- សមត្ថភាពវិជ្ជាជីវៈ និងការសហការក្រុម
- តម្លាភាពនិងគណនេយ្យភាព
- លើកកម្ពស់ស្វ័យភាពវិជ្ជាជីវៈថែទាំក្នុងព្រះរាជាណាចក្រកម្ពុជា

# ផ្នែកទី៤

# ការវិភាគស្ថានភាព ចំណុចខ្លាំង ចំណុចខ្វះខាត ឱកាស និងការប្រឈម

**( SWOT-Analysis )**

## ១. ការវិភាគយុទ្ធសាស្ត្រ (ការវិភាគលើកត្តាអត្តនោម័ត និងសត្យាម័ត) (SWOT-Analysis) របស់ គ.គិ.ក

ការវិភាគលើកត្តាអត្តនោម័ត និងសត្យានុម័ត ជាវិធីវិភាគមួយដ៏មានសារៈសំខាន់សម្រាប់វិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការប្រឈមនៃស្ថានភាពបច្ចុប្បន្នរបស់ គ.គិ.ក។ ចំណុចខ្លាំងគឺជាកត្តាផ្ទៃក្នុងដែលធ្វើឱ្យ គ.គិ.ក មានដំណើរការទៅមុខ ចំណែកឯចំណុចខ្សោយគឺជាកត្តាផ្ទៃក្នុងដែលរាំងស្ទះដល់ដំណើរការ និងការអភិវឌ្ឍរបស់ គ.គិ.ក។ ដូចនេះ ផែនការយុទ្ធសាស្ត្រត្រូវផ្តោតលើសកម្មភាពទាំងឡាយសំដៅពង្រឹងចំណុចខ្លាំងដោយកាត់បន្ថយឬលុបបំបាត់ចំណុចខ្សោយ។

ឱកាសគឺជាកត្តាផ្ទៃក្រៅដែលផ្តល់ផលវិជ្ជមាន ចំណែកឯការប្រឈមគឺជាកត្តាផ្ទៃក្រៅដែលផលអវិជ្ជមានដល់ គ.គិ.ក។ កត្តាទាំងពីរនេះអាចរងឥទ្ធិពលពីបរិយាកាសខាងក្រៅនៃ គ.គិ.ក។ ការកំណត់កត្តាទាំងនេះធ្វើឱ្យងាយស្រួលដល់ការបង្កើតយុទ្ធសាស្ត្រដើម្បីទាញយកផលប្រយោជន៍ពីឱកាស និងសម្រាលពីការប្រឈមទាំងនោះ។

គ.គិ.ក សម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សំគាល់តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រទី២ (២០១៧-២០១៩)។ ទោះជាយ៉ាងណាក្តី ក៏នៅមានចំណុចជាច្រើនទៀតដែលត្រូវកសាងនិងអភិវឌ្ឍបន្ថែមទៀតក្នុងផែនការយុទ្ធសាស្ត្រដំនាក់កាលទី៣(២០២១-២០២៥) នេះ។តារាងខាងក្រោមនេះបង្ហាញពីការវិភាគលើកត្តាអត្តនោម័តនិងសត្យានុម័តរបស់ គ.គិ.ក។

## ការវិភាគលើកត្តាអត្ថនោម័ត និងសត្យានុម័ត (SWOT-Analysis) របស់ គ.គិ.ក

### ចំណុចខ្លាំង

- ព្រះរាជក្រមស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលឆ្នាំ ២០១៦
- ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាគិលានុបដ្ឋាកកម្ពុជា
- មានរចនាសម្ព័ន្ធគ្រប់គ្រង រាជធានី ខេត្ត ភូមិភាគ និងថ្នាក់ជាតិ
- មានការប្រជុំភូមិភាគនិងថ្នាក់ជាតិប្រចាំឆ្នាំ
- មានប្រព័ន្ធចុះបញ្ជិកា(RMS)
- មានក្របខ័ណ្ឌនិយ័តកម្មនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD)
- មានផែនការយុទ្ធសាស្រ្តនិងផែនការសកម្មភាពច្បាស់លាស់
- ប្រធានមន្ទីរសុខាភិបាល និងប្រធានមន្ទីរពេទ្យគាំទ្រ គ.គិ.ក
- ចូលរួមក្នុងការកែលម្អកម្មវិធីសិក្សារបស់គិលានុបដ្ឋាក
- សមាជិក គ.គិ.ក គាំទ្រដល់ការចុះបញ្ជិកាគិលានុបដ្ឋាក
- គិលានុបដ្ឋាក-យិកាចូលរួម និងចុះបញ្ជិកា ជាមួយ គ.គិ.ក
- យុទ្ធសាស្រ្តក្រុមប្រឹក្សាសុខាភិបាលឆ្នាំ ២០១៥-២០២០

### ចំណុចខ្សោយ

- មិនមានថវិកាដើម្បីជ្រើសរើសបុគ្គលិក និងគាំទ្រដល់ប្រតិបត្តិការងារ
- ពុំទាន់មានដែនកំណត់នៃការថែទាំសម្រាប់គិលានុបដ្ឋាក
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យលើចំនួនគិលានុបដ្ឋាកដែលបានចុះបញ្ជីនៅមានកម្រិត
- ពុំទាន់មាននីតិវិធីដែលទាក់ទងទៅនឹងពាក្យបណ្តឹងលើកំហុសវិជ្ជាជីវៈ
- ការយល់ដឹងនូវមានកម្រិតថាតើ គ.គិ.ក ជាអ្វី ហើយអ្វីដែល គ.គិ.ក ធ្វើសម្រាប់សាធារណជន និងជាពិសេសគិលានុបដ្ឋាក-យិកា
- យន្តការការអនុវត្តគោលការណ៍ណែនាំ CPD នៅមានកំរិត
- មិនទាន់មានលទ្ធភាពត្រួតពិនិត្យនិងវាយតម្លៃពីគុណភាពនៃការបណ្តុះបណ្តាលមូលដ្ឋាន
- ប្រព័ន្ធគ្រប់គ្រងពុំទាន់បានអនុវត្តន៍គ្រប់ជ្រុងជ្រោយ
- សមត្ថភាពរបស់សមាជិក គ.គិ.ក នៅមានកម្រិត

CAMBODIA COUNCIL OF NURSES

## ឱកាស

- ច្បាប់ថ្មីស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលឆ្នាំ ២០១៦ (ការពិន័យលើការចុះបញ្ជី និងការផ្តល់អាជ្ញាបណ្ណ)
- កិច្ចសហប្រតិបត្តិការល្អជាមួយបណ្តារដ្ឋជាសមាជិកអាស៊ានទាំងអស់តាមរយៈការចូលរួមក្នុងកិច្ចប្រជុំ AJCCN និងកិច្ចប្រជុំសម្របសម្រួលផ្សេងៗទៀត
- ការគាំទ្រពីស្ថាប័នជាតិ និងអន្តរជាតិជាពិសេសពីក្រសួងសុខាភិបាល
- មានការចូលរួមគាំទ្រពីអង្គការដៃគូដូចជា FHI360, GIZ and WHO
- ការធ្វើឱ្យប្រសើរឡើងលើប្រព័ន្ធឌីជីថល (គេហទំព័រ និងFB)
- ប្រព័ន្ធផ្តល់អាជ្ញាបណ្ណឱ្យស្របតាមច្បាប់ថ្មី
- កែសម្រួលដំណើរការចុះឈ្មោះដើម្បីឱ្យងាយស្រួលជាងមុន

## ការគំរាមកំហែង

- ប្រព័ន្ធត្រួតពិនិត្យលើការចុះបញ្ជិកា និងការផ្តល់អាជ្ញាបណ្ណ
- កិច្ចសហប្រតិបត្តិការពីក្រសួងសុខាភិបាលលើការអនុវត្តច្បាប់ថ្មី
- ខ្វះបុគ្គលិកជំនាញធ្វើការពេញម៉ោងលើការចុះបញ្ជិកា និងការផ្តល់អាជ្ញាបណ្ណ (ទាំងលើក្រដាស និងតាមបច្ចេកវិទ្យាអនឡាញ
- ខ្វះវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លីចាប់ពី៣ខែឡើង
- ពុំមានការិយាល័យអចិន្ត្រៃយ៍នៅ រាជធានី ខេត្ត
- កិច្ចសហប្រតិបត្តិការនៅមានកំណត់រវាង គ.គិ.ក និងតំណាងគិលានុបដ្ឋាកនៅតាមមន្ទីរពេទ្យ
- ការប្តេជ្ញាចិត្តនៅតិចតួចពីមន្ត្រីរបស់ក.គិ.ខ

## ២. ការគំរាមកំហែង

- សមត្ថភាព និងពេលវេលានៅមានកំណត់សម្រាប់បុគ្គលិក និងសមាជិករបស់ គ.គិ.ក
- ការខ្វះខាតនូវធនធានបច្ចេកទេស និងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុ
- គ្មានប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ និងគ្មានទីតាំងការិយាល័យជាអចិន្ត្រៃយ៍នៅរាជធានីខេត្តសម្រាប់ធ្វើការប្រតិបត្តិការងារប្រចាំថ្ងៃ។
- គិលានុបដ្ឋាកភាគច្រើនមិនយល់ពីភាពចាំបាច់ និងភាពខុសគ្នារវាងគណៈគិលានុបដ្ឋាក និងសមាគមគិលានុបដ្ឋាក
- ជំងឺរាតត្បាតដែលពន្យឺតសកម្មភាពចាំបាច់នានារបស់គណៈគិលានុបដ្ឋាក

## ៣. គោលបំណង និងផ្នែកនៃការងារ

តាមការវិភាគលើកត្តាអត្តនោម័ត និងសត្យានុម័ត (SWOT) របស់ គ.គិ.ក ផែនការយុទ្ធសាស្ត្រ ទី III បានដាក់ចេញនូវតម្រូវការសម្រាប់អភិវឌ្ឍ និងពង្រឹងលើផ្នែក៤សំខាន់ៗ៖

- ស្តង់ដារវិជ្ជាជីវៈ
  - ការកំណត់ និងថែរក្សាស្តង់ដារថែទាំសុខភាពសម្រាប់ការពារសុវត្ថិភាពសាធារណៈ
  - ការធានានូវសម្បទាសមស្របសម្រាប់ប្រកបវិជ្ជាជីវៈរបស់គិលានុបដ្ឋាក
- ប្រព័ន្ធការចុះបញ្ជិកានិងការផ្តល់អាជ្ញាបណ្ណ
  - ការបង្កើនចំនួននៃការចុះបញ្ជិកាបស់គិលានុបដ្ឋាក
  - ការផ្តល់អាជ្ញាបណ្ណដល់គិលានុបដ្ឋាក
  - ពេលបន្តអាជ្ញាបណ្ណដល់គិលានុបដ្ឋាកត្រូវបំពេញឱ្យបាន៦០ពិន្ទុក្នុងរយៈពេលបីឆ្នាំ
- ការអភិវឌ្ឍ និងការកសាងសមត្ថភាពស្ថាប័ន
  - ការចូលរួមពីភាគីពាក់ព័ន្ធដើម្បីការអភិវឌ្ឍនៃកម្លាំងពលកម្មដែលមានសមត្ថភាព និងអាចបត់បែនបាន
  - យុទ្ធសាស្ត្រទំនាក់ទំនងតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍
- ការអភិវឌ្ឍ និងការកសាងសមត្ថភាពបុគ្គល
  - ការបង្ហាញភាពជាអ្នកដឹកនាំជាតិ និងអន្តរជាតិក្នុងបទប្បញ្ញត្តិនៃការថែទាំ
  - ការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសដើម្បីកសាងសមត្ថភាពក្រុមប្រឹក្សាដើម្បីឈានទៅទទួលបានចំនួនគិលានុបដ្ឋាកក្នុងកម្រិតមួយ និងប្រកបដោយគុណភាព។

## ក. ស្តង់ដារវិជ្ជាជីវៈ

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ គ.គិ.ក បានបង្កើតស្តង់ដារមួយចំនួនដូចជាក្រមសីលធម៌មការថែទាំ ស្តង់ដារនៃការថែទាំ ស្តង់ដារសមត្ថភាពស្នូលនៃការថែទាំ។ល។ គ.គិ.ក នឹងបន្តបង្កើតគោលការណ៍ណែនាំ ស្តង់ដារ និងសៀវភៅណែនាំបន្ថែមទៀតដើម្បីលើកកម្ពស់គុណភាពគិលានុបដ្ឋាកដើម្បីឈានដល់ស្តង់ដារជាតិ និងអន្តរជាតិ។ គ.គិ.ក នឹងរៀបចំការបណ្តុះបណ្តាលជាប្រព័ន្ធ និងស៊ីជម្រៅលើស្តង់ដារ គោលការណ៍ណែនាំ និងសៀវភៅណែនាំទាំងនោះដល់គិលានុបដ្ឋាកដែលបានជ្រើសរើស។

គ.គិ.ក មិនត្រឹមតែផ្តោតលើបរិមាណនៃគិលានុបដ្ឋាកដែលបានចុះបញ្ជិកានោះទេ ថែមទាំងលើគុណភាព និងប្រសិទ្ធភាពនៃសេវាថែទាំផងដែរ។ ការធ្វើឱ្យប្រសើរឡើង និងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើសមត្ថភាព ចំណេះដឹងនៃស្តង់ដារវិជ្ជាជីវៈ និងជំនាញផ្សេងៗទៀតគឺជាភារកិច្ចអាទិភាពសម្រាប់ គ.គិ.ក ក្នុងការធ្វើឱ្យគិលានុបដ្ឋាកក្លាយជាអ្នកជំនាញដែលមានសមត្ថភាព និងអាចជឿទុកចិត្តបានតាមស្តង់ដារអន្តរជាតិតាមរយៈការបង្កើតគោលការណ៍ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (Continuing Professional Development "CPD") សម្រាប់គិលានុបដ្ឋាកហើយអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺដំណើរការនៃការអនុវត្ត CPD។

## ខ. ប្រព័ន្ធការចុះបញ្ជិកា និងការផ្តល់អាជ្ញាបណ្ណ

នៅខែវិច្ឆិកា ឆ្នាំ២០១៦ ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ត្រូវបានអនុម័តដាក់ឱ្យអនុវត្តដោយព្រះរាជក្រមលេខ នស/រកម/០១៤ ដែលចែងផ្តោតសំខាន់លើអង្គភាពដែលទទួលខុសត្រូវលើការចុះបញ្ជិកា និងផ្តល់អាជ្ញាបណ្ណ។អ្នកជំនាញសុខាភិ
បាលទាំងអស់ដែលមានបំណងប្រកបវិជ្ជាជីវៈត្រូវចុះបញ្ជិកា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈជាមួយក្រុមប្រឹក្សាវិជ្ជាជីវៈដែលពាក់ព័ន្ធរៀងៗខ្លួន។ គ.គិ.ក ត្រូវធ្វើឱ្យប្រសើរឡើងលើប្រព័ន្ធការចុះបញ្ជិកានាពេលបច្ចុប្បន្នដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលសម្រាប់គិលានុបដ្ឋាកដែលចុះបញ្ជិកានិងបង្កើតប្រព័ន្ធផ្តល់អាជ្ញាបណ្ណសម្រាប់គិលានុបដ្ឋាកដែលបានចុះបញ្ជិកាទាំងអស់។

## គ. ការអភិវឌ្ឍ និងការកសាងសមត្ថភាពស្ថាប័ន

ការកសាងសមត្ថភាពគឺជាតម្រូវការចាំបាច់បំផុតរបស់ គ.គិ.ក។ រចនាសម្ព័ន្ធអង្គភាព និងប្រតិបត្តិការរបស់ គ.គិ.ក ត្រូវពង្រឹងតាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍ដែលទទួលបានពីក្រុមប្រឹក្សាគិលានុបដ្ឋាកដ៏ទៃទៀតក្នុងអាស៊ានក៏ដូចជាប្រទេសផ្សេងៗទៀត។

ភាពជាដៃគូរជាមួយស្ថាប័នដែលមានបទពិសោធន៍នៅក្នុងតំបន់ និងទូទាំងពិភពលោកត្រូវតែយកមកពិចារណាសម្រាប់ គ.គិ.ក ដើម្បីរក្សា និងពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយក្រុមប្រឹក្សាគិលានុបដ្ឋាកអាស៊ាន និងក្រុមប្រឹក្សាគិលានុបដ្ឋាកអន្តរជាតិ (ICN) ក៏ដូចជាការចូលរួមជាមួយគណៈកម្មាធិការសម្របសម្រួលរួមអាស៊ានលើសេវាថែទាំ (AJCCN)។ គ.គិ.ក ក៏បានបង្កើតទំនាក់ទំនងជាមួយក្រុមប្រឹក្សាគិលានុបដ្ឋាកផ្សេងៗទៀតក្នុងតំបន់ដើម្បីផ្លាស់ប្តូរគំនិត បទពិសោធន៍ និងការអនុវត្តល្អៗ។ ចំណេះដឹងប្រភេទនេះមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់ គ.គិ.ក ដើម្បីកសាងសមត្ថភាពរបស់ខ្លួន។

យុទ្ធសាស្ត្រនេះមានគោលដៅកសាង និងពង្រឹងកេរ្តិ៍ឈ្មោះរបស់ គ.គិ.ក។ គ.គិ.ក ត្រូវតែជាស្ថាប័នមួយដែលទទួលបានការគោរព និងកោតសរសើរ។ ការងាររបស់ គ.គិ.ក មានសារៈសំខាន់ និងមានប្រសិទ្ធភាពដរាបណាក្រសួងសុខាភិបាល គិលានុបដ្ឋាក-យិកា និងសាធារណជនគាំទ្រ និងទទួលស្គាល់ពីតម្លៃ និងគុណប្រយោជន៍នៃការងាររបស់ គ.គិ.ក ។ ដើម្បីឈានទៅសម្រេចបានគោលដៅនេះ គ.គិ.ក ត្រូវពង្រឹងរចនាសម្ព័ន្ធផ្ទៃក្នុង និងទំនាក់ទំនងផ្ទៃក្រៅ។ ការពង្រឹងរចនាសម្ព័ន្ធផ្ទៃក្នុងនេះសំដៅដល់តួនាទី និងការទទួលខុសត្រូវរបស់សមាជិក គ.គិ.ក ប្រព័ន្ធការចុះបញ្ជិកា និងការផ្តល់អាជ្ញាបណ្ណ ប្រព័ន្ធការគ្រប់គ្រងទិន្នន័យ និងប្រព័ន្ធបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យា (ICT)។ គ.គិ.ក ត្រូវធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជិកានាពេលបច្ចុប្បន្ន និងបង្កើតប្រព័ន្ធផ្តល់អាជ្ញាបណ្ណឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈដើម្បីឱ្យមានគុណភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ខ្លួន។ ប្រព័ន្ធការគ្រប់គ្រងទិន្នន័យសំដៅលើការគ្រប់គ្រងប្រព័ន្ធទិន្នន័យឌីជីថលរបស់គិលានុបដ្ឋាកដែលបានចុះបញ្ជិកាទាំងគិលានុបដ្ឋាកក្នុងស្រុក និងបរទេស។ ប្រព័ន្ធ ICT ដែលមានប្រសិទ្ធភាពនឹងត្រូវបង្កើតឡើងដើម្បីជួយគាំទ្រដល់ការងាររដ្ឋបាលដើម្បីឱ្យមានទំនាក់ទំនងល្អទាំងក្នុង និងក្រៅ។

ភារកិច្ចទាំងនេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ គ.គិ.ក ដើម្បីមានសមត្ថភាពវិជ្ជាជីវៈដែលអាចជឿទុកចិត្តបាននិងត្រូវបានទទួលស្គាល់ដោយអ្នកពាក់ព័ន្ធដទៃទៀតជាពិសេសគិលានុបដ្ឋាក និងក្រសួងសុខាភិបាល។

**ឃ. ការអភិវឌ្ឍ និងការកសាងសមត្ថភាពបុគ្គល**

ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់សមាជិកអាចត្រូវបានពង្រឹងតាមរយៈការបណ្ដុះបណ្ដាលនៅក្នុងនិងក្រៅប្រទេស ឬតាមរយៈកិច្ចសហប្រតិបត្តិការជាមួយនិងស្ថាប័នបណ្ដុះបណ្ដាល និងក្រុមប្រឹក្សាគិលានុបដ្ឋាកក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ។ ការវាយតម្លៃលើតម្រូវការបណ្ដុះបណ្ដាលទាមទារនូវការត្រួតពិនិត្យឡើងវិញ ការកែតម្រូវ និងការធ្វើបច្ចុប្បន្នភាពជាប្រចាំពីមួយអាណត្តិ ទៅមួយអាណត្តិទៀត ដើម្បីផ្ដល់នូវកម្មវិធីបណ្ដុះបណ្ដាលជាក់លាក់ស្របតាមតម្រូវការរបស់សមាជិក គ.គិ.ក និងដើម្បីបំពេញនូវចន្លោះខ្វះខាតក្នុងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា គិលានុបដ្ឋាក និងជំនាញពាក់ព័ន្ធ។ នៅពេលដែលសមាជិកមានចំណេះដឹង និងជំនាញដែលពាក់ព័ន្ធនឹងការងារ គ.គិ.ក នឹងមានសមាជិកប្រកបដោយសមត្ថភាពវិជ្ជាជីវៈសម្រាប់បំពេញការងារដែលទទួលបានលទ្ធផលខ្ពស់។

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.១.៣.រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តដល់គ្រប់ពេងចក្រ សហគ្រាស និង សេវាឯកជននានា តាមរយៈជួបផ្ទាល់ ឬ បណ្តាញសង្គម | x | | | | | | | x | | | | | | x | | | | | | | ចំនួនសិក្ខាសាលាដែលបានរៀបចំ | CCN | 9,000.00 |
| ១.១.៤. រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីដែនកំណត់ និង និយាម នៃការអនុវត្តរបស់គិលានុបដ្ឋាកដល់គ្រប់ពេងចក្រ សហគ្រាស និងសេវាឯកជននានា តាមរយៈជួបផ្ទាល់ ឬ បណ្តាញសង្គម | | | | x | | | | x | | | | | x | | | | | x | | | ចំនួនសិក្ខាសាលាដែលបានរៀបចំ | CCN | 12,000.00 |



CAMBODIA COUNCIL OF NURSES

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.១.៥.រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាក (ថ្មី) ដល់នាយកដ្ឋានពាក់ព័ន្ធ គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល មន្ទីរពេទ្យ និង មណ្ឌលសុខភាព នៅទូទាំងប្រទេសតាមរយៈជួបផ្ទាល់ ឬ បណ្តាញសង្គម។ | | | | x | x | | | | | | | | | | | | | | | | ចំនួនសិក្ខាសាលា ដែលបាន រៀបចំ | CCN | 6,000.00 |

**ទិសដៅទី២៖** បង្កើនការប្រើប្រាស់ការចុះបញ្ជិកាតាមប្រពន្ធ័គ្រប់គ្រងទិន្ន័យគិលានុបដ្ឋាក (RMS)

| យុទ្ធសាស្រ្ត និង សកម្មភាព អាទិភាព | គោលដៅអនុវត្តប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | សូចនាករ | គោលដៅ សរុប | ថវិកាប៉ាន់ស្មាន (USD) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | ២០២២ | | | | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | | | | |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | | |
| ២.១បណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ការចុះបញ្ជិកាតាមប្រពន្ធ័គ្រប់គ្រងទិន្ន័យគិលានុបដ្ឋាក (RMS) | | | | | | | | | | | | | | | | | | | | | | | |
| ២.១.១ផ្សព្វផ្សាយ និងបង្រៀនពីរបៀបចុះបញ្ជិកាតាមប្រពន្ធ័គ្រប់គ្រងទិន្ន័យគិលានុបដ្ឋាក (RMS)ដល់គិលានុបដ្ឋាកដែលបំពេញការងារនៅរោងចក្រ សហគ្រាស និងសេវាឯកជននានា | x | | x | | | x | | | x | | | | | | x | | | x | | | ចំនួនសិក្ខាសាលាដែលបានរៀបចំ | CCN | 24,000.00 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.១.២លើកទឹកចិត្តអោយរោងចក្រសហគ្រាស និងសេវាឯកជននានាឱ្យមានអ្នកសម្របសម្រួលក្នុងការចុះបញ្ជិកាតាមប្រពន្ធ័គ្រប់គ្រងទិន្នន័យរបស់គិលានុបដ្ឋាក (RMS) | | x | | | | x | | | | | x | | | | x | | | x | | | ចំនួនប្រជុំ និង បញ្ជីឈ្មោះអ្នកសម្របសម្រួលតាមរោងចក្រសហគ្រាស | CCN | **1,500.00** |

**ទិសដៅទី៣៖** ជំរុញការចុះបញ្ជិការបស់គិលានុបដ្ឋាកដែលបម្រើការងារទាំងគ្រឹះស្ថានសាធារណៈ ឯកជន រោងចក្រសហគ្រាស អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ

| យុទ្ធសាស្ត្រ និង សកម្មភាព អាទិភាព | គោលដៅអនុវត្តប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | សូចនាករ | គោលដៅ សរុប | ថវិកាប៉ាន់ស្មាន (USD) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | ២០២២ | | | | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | | | | |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | | |
| ៣.១រៀបចំសេចក្តីជូនដំណឹងដល់ប្រធានអង្គភាព ម្ចាស់រោងចក្រសហគ្រាស ប្រធានអង្គការក្រៅ រដ្ឋាភិបាលផ្សេងៗស្តីពីការតម្រូវឱ្យចុះបញ្ជិកានិងទទួលអាជ្ញាបណ្ណរបស់គិលានុបដ្ឋាក (ខ្មែរនិងបរទេស) ដែលបំពេញការងារនៅក្នុងប្រទេសកម្ពុជា | | | | | | | | | | | | | | | | | | | | | | | |
| ៣.១.១ រៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់គិលានុបដ្ឋាកទាំងអស់ពីការចុះបញ្ជិកានិងផ្តល់អាជ្ញាបណ្ណ(RMS) | | x | | | | | x | | | x | | | | | x | | | | | x | ចំនួនសិក្ខាសាលាដែលបានរៀបចំ | CCN | 20,000.00 |
| ៣.១.២ រៀបចំបណ្តុះបណ្តាលដល់គិលានុបដ្ឋាក ទាំងអស់ស្តីពីប្រព័ន្ធនៃការចុះបញ្ជិកានិងផ្តល់អាជ្ញាបណ្ណ (RMS) | x | | x | | x | | x | | x | | x | | x | | x | | x | | x | | ចំនួនបណ្តុះបណ្តាល | CCN & PCN | 40,000.00 |

**ទិសដៅទី៤៖** ជម្រុញការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគិលានុបដ្ឋាកដោយគោរពតាមគោលការណ៍ណែនាំនិយ័តកម្មការអភិវឌ្ឍបន្ត

| យុទ្ធសាស្ត្រ និង សកម្មភាព អាទិភាព | គោលដៅអនុវត្តប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | សូចនាករ | គោលដៅសរុប | ថវិកាប៉ាន់ស្មាន (USD) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | ២០២២ | | | | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | | | | |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | | |
| ៤.១. ផ្សព្វផ្សាយដល់អង្គភាពឬ ដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត | | | | | | | | | | | | | | | | | | | | | | | |
| ៤.១.១.រៀបចំសិក្ខាសាលាផ្សព្វផ្សាយដល់អង្គភាពឬ ដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍ វិជ្ជាជីវៈបន្ត | | x | | x | | x | | x | | x | | x | | x | | x | | x | | x | ចំនួនសិក្ខាសាលាដែលបានរៀបចំ | CCN, PCN | 40,000.00 |
| ៤.១.២. រៀបចំការប្រជុំជាមួយគណៈកម្មការវាយតម្លៃរបស់គណៈគិលានុបដ្ឋាកកម្ពុជាដើម្បីពិនិត្យឯកសារដែលបានដាក់ស្នើសុំធ្វើការបណ្តុះបណ្តាល | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | ចំនួនកិច្ចប្រជុំពិនិត្យឯកសារស្នើសុំបណ្តុះបណ្តាល | CCN | 6,000.00 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.១.៣. រៀបចំប្រជុំជាមួយប្រធានអង្គភាពពាក់ព័ន្ធជាទៀងទាត់ស្តីពីយន្តការនៃការបន្តអាជ្ញាបណ្ណ | | x | | x | | x | | x | | x | | x | | x | | x | | x | | x | ចំនួនកិច្ចប្រជុំ | CCN | 6,000.00 |



CAMBODIA COUNCIL OF NURSES

**ទិសដៅទី៥៖** ពង្រឹងការចុះអភិបាលកិច្ចនៅតាមការិយាល័យគណៈគិលានុបដ្ឋាកនៅទូទាំងប្រទេស

| យុទ្ធសាស្ត្រ និង សកម្មភាពអាទិភាព | គោលដៅអនុវត្តប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | សូចនាករ | គោលដៅសរុប | ថវិកាប៉ាន់ស្មាន (USD) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | ២០២២ | | | | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | | | | |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | | |
| ៥.១. អភិបាលកិច្ច តាមការិយាល័យគណៈគិលានុបដ្ឋាកនៅទូទាំងប្រទេស | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.១. ចុះធ្វើអភិបាលកិច្ច (ពិនិត្យមើលអាជ្ញាបណ្ណ និងសុពលភាពនៃអាជ្ញាបណ្ណ និងក្រមសីលធម៌វិជ្ជាជីវៈគិលានុបដ្ឋាក) | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | ចំនួនដងចុះធ្វើអភិបាលកិច្ច | PCN | 6,000.00 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥.១.២. តាមដានដល់គ្រប់ការិយាល័យគណ:គិលានុបដ្ឋាកទូទាំងប្រទេស ក្នុងការចុះធ្វើអភិបាលកិច្ចសកម្មភាពការងារគណ:គិលានុបដ្ឋាក | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | ចំនួនដងចុះធ្វើអភិបាលកិច្ច | CCN | 6,000.00 |

**ទិសដៅទី៦៖** បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិ និងស្វែករកជំនួយសម្រាប់ឱកាសក្នុងការធ្វើការសិក្សាស្រាវជ្រាវ

| យុទ្ធសាស្ត្រ និង សកម្មភាព អាទិភាព | គោលដៅអនុវត្តប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | សូចនាករ | គោលដៅ សរុប | ថវិកាប៉ាន់ស្មាន (USD) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | ២០២២ | | | | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | | | | |
| | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | | | |
| ៦.១. កិច្ចសហប្រតិបត្តិការជាមួយដៃគូរពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិ និងស្វែករកជំនួយសម្រាប់ ឱកាសក្នុងការធ្វើការសិក្សាស្រាវជ្រាវ | | | | | | | | | | | | | | | | | | | | | | | |
| ៦.១.១.ស្វែងរកដៃគូរអភិវឌ្ឍជាតិ អន្តរជាតិដើម្បីគាំទ្រសកម្មភាពគណ:គិលានុបដ្ឋាកកម្ពុជាទាំងបច្ចេកទេសនិងថវិកា | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | ចំនួនដៃគូរអភិវឌ្ឍ | CCN, PCN | 12,000.00 |
| ៦.១.២ សហការជាមួយដៃគូរជាតិនិងអន្តរជាតិដើម្បីរៀបចំធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទផ្សេងៗទាក់ទងនឹងគិលានុបដ្ឋាក | | | | | | x | | | | | x | | | | | | | | x | | ចំនួនការសិក្សាស្រាវជ្រាវ | CCN, PCN and Partners | 12,000.00 |

| | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦.១.៣ សហការជាមួយដៃគូពាក់ព័ន្ធទាក់ទងនិងការបណ្តុះបណ្តាលមុនពេលបម្រើការងារ និងបណ្តុះបណ្តាលកំពុងបម្រើការងារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | ចំនួនដៃគូរសហការណ៍ | CCN, PCN | NA |
| ថវិកាប៉ាន់ស្មានសរុប (Total Estimated Budget) | | | | | | | | | | | | | | | | | | | | | | 260,500.00 | |

# សេចក្តីបន្ថែមទី ១៖ បញ្ជីឈ្មោះសមាជិកក្រុមការងារបច្ចេកទេស

## តំណាងមកពីគណៈគិលានុបដ្ឋាកកម្ពុជា

| | |
|---|---|
| ១.លោក អនុបណ្ឌិត អ៊ុន សាន | ប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ២.លោក មាស សារិទ្ធ | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៣.លោក ថៃ សុវណ្ណារ៉ា | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៤. លោក ប្រុញ សុមិត្ត | អគ្គលេខាធិការរងគណៈគិលានុបដ្ឋាកកម្ពុជា |
| ៥. លោកស្រី ម៉ៅ តាន់ណារី | អគ្គហេរញ្ញិកគណៈគិលានុបដ្ឋាកកម្ពុជា |
| ៦. លោក ហ៊ិន សេរីវឌ្ឍនា | អគ្គហេរញ្ញិករងគណៈគិលានុបដ្ឋាកកម្ពុជា |

## តំណាងមកពីមន្ទីរពេទ្យថ្នាក់ជាតិ

| | |
|---|---|
| ១.លោក គឹម ចន្ថា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យកុមារជាតិ |
| ២.លោក ឌុច សុខា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត |
| ៣.លោក ជី សម្បត្តិ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យកាល់ម៉ែត |
| លោ.៤កស្រី ប៉ែន មុំ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៥.លោកស្រី កង ឡុងធវីវណ្ណ | អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យ មិត្តភាពកម្ពុជាចិនព្រះកុសុមៈ |

## តំណាងមកពីភូមិភាគនិងខេត្ត

| | |
|---|---|
| ១.លោក មៀច លឹមហួរ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគកំពង់ចាម |
| ២.លោក យក់ សុត្ថា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគបាត់ដំបង |
| ៣. លោក ហឿ សេធិល | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគស្ទឹងត្រែង |
| ៤. លោក សុខ ត្រា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគកំពត |
| ៥. លោកស្រី អ៊ឹម វណ្ណនី | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគភ្នំពេញ-កណ្តាល |
| ៦.លោក អ៊ឹម សំបូ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្តប៉ៃលិន |
| ៧.លោកស្រី ឈន់ សេដ្ឋា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្តកំពង់ចាម |
| ៨.លោក លឹម សុភក្តិ | អនុប្រធានក្រុមប្រឹក្សា គណៈគិលានុបដ្ឋាកខេត្តត្បូងឃ្មុំ |

## តំណាងមកពីមន្ទីរពេទ្យរបស់អង្គការក្រៅរដ្ឋាភិបាល

| | |
|---|---|
| លោក អឿន ចន្ទី | តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យអង្គការក្រៅរដ្ឋាភិបាលមជ្ឈមណ្ឌលនៃក្តីសង្ឃឹមព្រះសីហនុ |
| លោក ដួង វិបុល | នាយកផ្នែកបណ្តុះបណ្តាលនៃមន្ទីរពេទ្យកុមារអង្គរ |

## ដៃគូអភិវឌ្ឍ

| | |
|---|---|
| ១.លោកអនុបណ្ឌិត លី ច័ន្ទវឌ្ឍនះ | ទីប្រឹក្សាបច្ចេកទេសនីយ័តកម្ម និងគាំទ្រការអភិវឌ្ឍន៍គណៈវិជ្ជាជីវៈសុខាភិបាលនៃគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក(USAID-EQHA) |
| ២.Dr. Edward Chappy | Senior Technical Advisor for Regulations and Accreditation USAID-EQHA |
| ៣.Assistant Prof. Jeff Lane | USAID-EQHA Consultant (University of Washington/I-TECH) |

# សេចក្តីបន្ថែមទី២៖ បញ្ជីឈ្មោះក្រុមការងារចូលរួមសិក្ខាសាលា ពិគ្រោះយោបល់

## តំណាងមកពីគណៈគិលានុបដ្ឋាកកម្ពុជា

| | |
|---|---|
| ១.លោកអនុបណ្ឌិត អ៊ុន សាន | ប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ២.លោក មាស សារិទ្ធ | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៣.លោក ថៃ សុវណ្ណារ៉ា | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៤. លោក ប្រុញ សុមិត្ត | អគ្គលេខាធិការរងគណៈគិលានុបដ្ឋាកកម្ពុជា |
| ៥. លោកស្រី ម៉ៅ តាន់ណារី | អគ្គហេរញ្ញិកគណៈគិលានុបដ្ឋាកកម្ពុជា |
| ៦. លោក ហ៊ុន សេរីវឌ្ឍនា | អគ្គហេរញ្ញិករងគណៈគិលានុបដ្ឋាកកម្ពុជា |

## តំណាងមកពីមន្ទីរពេទ្យថ្នាក់ជាតិ

| | |
|---|---|
| ១.លោក គឹម ចន្ថា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យកុមារជាតិ |
| ២.លោក ឌុច សុខា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត |
| ៣.លោក ជី សម្បត្តិ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យកាល់ម៉ែត |
| .៤លោកស្រី ប៉ែន មុំ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកសាកលវិទ្យាល័យវិទ្យាសាស្រ្ត សុខាភិបាល |
| ៥.លោកស្រី កង ឡុងឆវីណ្ណ | អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យ មិត្តភាពកម្ពុជាចិន ព្រះកុសុមៈ |

## តំណាងមកពីភូមិភាគនិងខេត្ត

| | |
|---|---|
| ១.លោក មៀច លឹមហួរ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគកំពង់ចាម |
| ២.លោក យក់ សុត្ថា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគបាត់ដំបង |
| ៣. លោក ហឿ សេធិល | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគស្ទឹងត្រែង |
| ៤. លោក សុខ ត្រា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគកំពត |
| ៥. លោកស្រី អ៊ឹម វណ្ណនី | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកភូមិភាគភ្នំពេញ-កណ្តាល |
| ៦.លោក អ៊ឹម សំបូ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្តប៉ៃលិន |
| ៧.លោកស្រី ឈន់ សេដ្ឋា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកខេត្តកំពង់ចាម |
| ៨.លោក លឹម សុភក្តិ | អនុប្រធានក្រុមប្រឹក្សា គណៈគិលានុបដ្ឋាកខេត្តត្បូងឃ្មុំ |

## តំណាងមកពីមន្ទីរពេទ្យរបស់អង្គការក្រៅរដ្ឋាភិបាល

| | |
|---|---|
| លោក អឿន ចន្ទី | តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកមន្ទីរពេទ្យអង្គការក្រៅរដ្ឋាភិបាលមជ្ឈមណ្ឌលនៃក្តីសង្ឃឹមព្រះសីហនុ |
| លោក ដួង វិបុល | នាយកផ្នែកបណ្តុះបណ្តាលនៃមន្ទីរពេទ្យកុមារអង្គរ |

## ដៃគូអភិវឌ្ឍ

| | |
|---|---|
| ១.លោកអនុបណ្ឌិត លី ច័ន្ទវឌ្ឍនៈ | ទីប្រឹក្សាបច្ចេកទេសនីយ័តកម្ម និងគាំទ្រការអភិវឌ្ឍន៍គណៈវិជ្ជាជីវៈសុខាភិបាលនៃគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក(USAID-EQHA) |
| ២.Dr. Edward Chappy | Senior Technical Advisor for Regulations and Accreditation USAID-EQHA |
| ៣.លោកស្រី ប្រាក់ ម៉ានីឡា | ទីប្រឹក្សាបច្ចេកទេសទទួលស្គាល់គុណភាពមូលដ្ឋានសុខាភិបាលនៃគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក(USAID-EQHA) |
| ៤. លោកវេជ្ជបណ្ឌិត ឡៅ ចន្ថា | ទីប្រឹក្សាបច្ចេកទេសទទួលស្គាល់គុណភាពនិងអាជ្ញាបណ្ណមូលដ្ឋានសុខាភិបាលរបស់គម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក(USAID-EQHA) |
| ៥. លោក អៀវ វឌ្ឍនៈ | មន្ត្រីគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក(USAID-EQHA) |



CAMBODIA COUNCIL OF NURSES

រៀបចំដោយ

# គណៈគិលានុបដ្ឋាកកម្ពុជា

គណៈគិលានុបដ្ឋាកកម្ពុជា

បោះពុម្ពលើកទី១ ដោយគណៈគិលានុបដ្ឋាកកម្ពុជា រាជធានីភ្នំពេញ ឆ្នាំ២០២១

http://CambodianCouncilofNurse.com/kh/ unsan888@gmail.com 095 901 902

សហការរៀបចំ និង ឧបត្ថម្ភដោយ

USAID FROM THE AMERICAN PEOPLE

fhi360 THE SCIENCE OF IMPROVING LIVES